វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# ព្រឹត្តិបត្រព័ត៌មានឆ្នាំ ២០២០

## សមិទ្ធផលគន្លឹះលើការកសាងនិងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការលើជំនាញគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ




### មាតិកា

១. វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ....................១
២. សមិទ្ធផលនៃការបណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាពឆ្នាំ ២០១៣-២០២០ .......២
៣. កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ...២
៤. កិច្ចសហការវាង វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍ ................៣
៥. កម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី ក្រោមកិច្ចសហការជាមួយក្រសួងស្ថាប័ន .......៥
៦. អនុស្សរណៈយោគយល់គ្នារវាង វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃ កហសវ និងដៃគូអភិវឌ្ឍជាតិ-អន្តរជាតិ ...................៧
៧. ការសិក្សាស្រាវជ្រាវស្តីពីការពិនិត្យលទ្ធភាពក្នុងការរៀបចំប្រព័ន្ធសិក្សាពីចម្ងាយ (Distance Learning System) ......................៨

## ១. វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្នុងក្របខណ្ឌស្ថាប័ន ការបណ្តុះបណ្តាលនិងវិក្រឹតការ លើមុខជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កន្លងមកត្រូវបានរៀបចំនិងអនុវត្តដោយតួអង្គផ្សេងៗគ្នាជាច្រើន ទៅតាមលទ្ធភាពនិងការចាំបាច់ ។ ក្នុងនោះវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលត្រូវបានបង្កើតឡើងដំបូងនៅឆ្នាំ ១៩៩៧ ក្រោមគំនិតផ្តួចផ្តើមរបស់ **កិត្តិបរិក្សបណ្ឌិត គាត ឈន់** អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** អតីតរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងដឹកនាំផ្ទាល់ដោយ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** អតីតនាយកវិទ្យាស្ថាន, គឺជាតួអង្គសំខាន់មួយដែលបានដើរតួនាទីយ៉ាងសកម្មលើការងារនេះ ។



ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប
រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្នុងដំណាក់កាលដំបូង វិទ្យាស្ថានសេដ្ឋកិច្ចនិហិរញ្ញវត្ថុជានាយកដ្ឋានមួយក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបានបំពេញមុខងារបណ្តុះបណ្តាល និង ហ្វឹកហ្វឺនចំណេះដឹង ជូនមន្ត្រីរាជការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើជំនាញសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជំនាញពាក់ព័ន្ធ ដោយមានការគាំទ្រខាងបច្ចេកទេសពីធនាគារពិភពលោក រួមនឹងស្ថាប័នដៃគូពាក់ព័ន្ធមួយចំនួនទៀត ។ បច្ចុប្បន្នផ្អែកតាមអនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០១៥ និង ប្រកាសលេខ ១០៥៨ សហវ.ប្រក ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៥ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានដំឡើងឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាននិងបំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការងារបណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាពលើជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សំដៅចូលរួមចំណែកអនុវត្តការបំពេញមុខងាររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាសេនាធិការឱ្យរាជរដ្ឋាភិបាល លើបេសកកម្មដឹកនាំ និងគ្រប់គ្រងលើវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងលើកតម្កើងជីវភាពប្រជាជន ដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារ និងសមធមិសង្គម ។

នៅក្នុងដំណើរការអនុវត្តការងារជាក់ស្តែង វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសហការជាមួយដៃគូជាតិ-អន្តរជាតិ ដើម្បីបង្កើនវិសាលភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងវិក្រឹតការសមត្ថភាព ឆ្លើយតបទៅនឹងតម្រូវការកសាងនិងអភិវឌ្ឍសមត្ថភាពធនធានមនុស្ស សម្រាប់រួមចំណែកអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។



ឯកឧត្តម អ៊ិន អេម នាយកវិទ្យាស្ថាន
សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ២. សមិទ្ធផលនៃការបណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាពឆ្នាំ ២០១៣- ២០២០

វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអនុវត្តមុខងារយ៉ាងសកម្ម លើការងារកសាងនិងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័ន លើមុខជំនាញចាំបាច់សម្រាប់អនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី២ និងទី៣ ។ នៅក្នុងដំណាក់កាលនេះកម្មវិធីបណ្តុះបណ្តាល របស់វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានផ្តោតជាសំខាន់ លើមុខជំនាញឯកទេសមូលដ្ឋាន និងជំនាញឯកទេសជាក់លាក់ដែលឆ្លើយតបទៅនឹងតម្រូវការរបស់ក្រសួងស្ថាប័ននីមួយៗ ។ កម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការសមត្ថភាពរបស់វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានផ្តោតលើមុខជំនាញរួមមាន÷ ថវិកាកម្មវិធី និងអង្គភាពថវិកា, កិច្ចលទ្ធកម្មសាធារណៈ, កិច្ចបញ្ជិកាគណនេយ្យ, របាយការណ៍ហិរញ្ញវត្ថុ, ការកត់ត្រាចលនាឥណទាន, សវនកម្ម, ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ, និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដែលសុទ្ធតែជាប្រធានបទដ៏សំខាន់ ក្នុងការពង្រឹងពង្រីកសមត្ថភាព និងលើកកម្ពស់ការយល់ដឹងជូនមន្ត្រីរាជការ ។ គិតត្រឹមឆ្នាំ ២០២០ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំវគ្គបណ្តុះបណ្តាលជូនមន្ត្រីរាជការគ្រប់ក្រសួងស្ថានប័ន អង្គភាពរាជធានី-ខេត្ត បានចំនួន **៣៤៤ វគ្គ** ក្នុងនោះមានវគ្គបណ្តុះបណ្តាលក្នុងប្រទេសសរុប **២៤៥ វគ្គ** និងក្រៅប្រទេសសរុប **៩៩ វគ្គ** និងមានសិក្ខាកាមចូលរួមសរុប **២២.៩២១ នាក់** ។ បច្ចុប្បន្នសិក្ខាកាមទាំងនោះ បាននិងកំពុងចូលរួមយ៉ាងសកម្មក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយឆន្ទៈខ្ពស់ ។











## ៣. វគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប
រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រោមការដឹកនាំចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់ របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារកសាងសមត្ថភាព របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**, ចាប់ពីឆ្នាំ ២០១៨ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំនិងអនុវត្តវគ្គបណ្តុះបណ្តាលស្តីពី **“ជំនាញបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ”** ក្នុងគោលដៅលើកកម្ពស់សមត្ថភាពជំនាញ និងពង្រឹងពង្រីកចំណេះដឹងបច្ចេកទេសសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនដល់សិក្ខាកាមគោលដៅជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការជំនាញដែលទទួលបន្ទុកការងារគ្រប់គ្រងថវិកា, ហិរញ្ញវត្ថុ, គណនេយ្យ, និងលទ្ធកម្មសាធារណៈ របស់ក្រសួងស្ថាប័ន នៃរាជរដ្ឋាភិបាលកម្ពុជា ។ ដំណើរការបណ្តុះបណ្តាលជាក់ស្តែង ត្រូវបានរៀបចំសម្របសម្រួលដោយវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរៀបចំនៅវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងទម្រង់ជាកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស រយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រ ដែលមានរយៈពេលពី ៧៨ ដល់ ៩០ ម៉ោងផ្តោតលើមុខជំនាញសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានរៀបចំ និងអនុវត្តដោយជោគជ័យស្របតាមស្មារតីផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាព ដំណាក់កាលទី ៣ ដោយសម្រេចបានវគ្គសិក្សាសរុប ៥៥ វគ្គ និងមានមន្ត្រីរាជការជាសិក្ខាកាមគោលដៅ ២.២០៩ នាក់ត្រូវបានជ្រើសរើសចូលរៀន និងមានសិក្ខាកាម ១.៤៦៣ នាក់ បានប្រឡងជាប់ដោយជោគជ័យ និងទទួលបានវិញ្ញាបនបត្របញ្ចប់ការសិក្សាពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅឆ្នាំ ២០១៨ និង ២០១៩ ហើយមានសិក្ខាកាម ៣០០ នាក់ កំពុងសិក្សានៅឆ្នាំ ២០២០ ។ វគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសនេះ គឺសម្រាប់សិក្ខាកាមគោលដៅជាមន្ត្រីរាជការដែលត្រូវបានតែងតាំង ប្រគល់ភារកិច្ច ឬត្រៀមទទួលការតែងតាំង ប្រគល់ភារកិច្ច លើមុខងារជា មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ, មន្ត្រីគ្រប់គ្រងកិច្ចលទ្ធកម្ម

សាធារណៈ, រដ្ឋទេយ្យករបុរេប្រទាន/រង, រដ្ឋទេយ្យករចំណូល/រង, មន្ត្រីគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ, ភ្នាក់ងារបើកផ្តល់ និង ភ្នាក់ងារបើកផ្តល់ជំនួស នៃអង្គភាពថវិកានៅថ្នាក់ជាតិនិង ថ្នាក់ក្រោមជាតិ រួមនឹងគ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ ។





## ៤.កិច្ចសហការខាងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ដៃគូអភិវឌ្ឍ

ក្រោមការដឹកនាំ និងណែនាំចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារកសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**, វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសហការជាមួយដៃគូអភិវឌ្ឍអន្តរជាតិមួយចំនួនក្នុងការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលាបណ្តុះបណ្តាល និងសិក្ខាសាលាចែករំលែកចំណេះដឹងជូនថ្នាក់ដឹកនាំកម្រិតបច្ចេកទេស និងមន្ត្រីជំនាញពាក់ព័ន្ធ ដោយទទួលបានលទ្ធផលប្រកបដោយជោគជ័យ ។

### ៤.១. កិច្ចសហការជាមួយការិយាល័យអភិវឌ្ឍសមត្ថភាព (CDOT) នៃមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)




នារសៀលថ្ងៃទី ២៧ ខែ កក្កដា និង ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០២០ ក្នុងកាលៈទេសៈនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ (COVID-19) វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហការជាមួយការិយាល័យអភិវឌ្ឍសមត្ថភាព (CDOT) នៃមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ប្រចាំប្រទេសថៃ បានរៀបចំបើកសិក្ខាសាលាបណ្តុះបណ្តាលពីចម្ងាយស្តីពី "**ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដាគណនេយ្យសាធារណៈអន្តរជាតិផ្អែកលើមូលដ្ឋានសាច់ប្រាក់**" ដោយមានការអញ្ជើញចូលរួមពី **ឯកឧត្តមបណ្ឌិត វង្ស ប៊ុនឥន្ទ្រាវុធ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ និង **ឯកឧត្តមនាយកវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងវាគ្មិនដែលជាអ្នកជំនាញជាន់ខ្ពស់នៃមូលនិធិរូបិយវត្ថុអន្តរជាតិ ព្រមទាំងមន្ត្រីរាជការទទួលបន្ទុកការងារពាក់ព័ន្ធគណនេយ្យសាធារណៈរបស់ក្រសួងស្ថាប័នចំនួន ១៥ ដែលមានសិក្ខាកាមចូលរួមសរុប **១២៤ នាក់**។ សិក្ខាសាលាបណ្តុះបណ្តាលនេះមានគោលបំណងចែករំលែកចំណេះដឹង និងសារសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុជូនដល់មន្ត្រីជំនាញដែលបំពេញពាក់ព័ន្ធគណនេយ្យសាធារណៈនៅតាមបណ្តាក្រសួងស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ។

### ៤.២. កិច្ចសហការជាមួយសាលារដ្ឋបាលសាធារណៈ (CSC) និងមូលនិធិតេម៉ាសេកអន្តរជាតិ (TFI) នៃប្រទេសសិង្ហបុរី

នាព្រឹកថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០២០ នៅវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលពីចម្ងាយស្តីពី "**ការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ (Development of Curriculum Design)**" ជូនគ្រូបង្គោលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ សិក្ខាសាលាបណ្តុះបណ្តាលនេះរៀបចំឡើងដោយមានកិច្ចសហការជាមួយសាលារដ្ឋបាលសាធារណៈ (CSC) និងមូលនិធិតេម៉ាសេកអន្តរជាតិ (TFI) នៃប្រទេសសិង្ហបុរី ក្នុងគោលបំណងដើម្បីពង្រឹងពង្រីកសមត្ថភាព និងលើកកម្ពស់ការយល់ដឹង និងដកស្រង់បទពិសោធន៍ពាក់ព័ន្ធនឹងការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ របស់សាលារដ្ឋបាលសាធារណៈ ប្រទេសសិង្ហបុរី ជូនគ្រូបង្គោលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាពិសេសដើម្បីចូលរួមចំណែកគាំទ្រការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស ក្នុងគោលដៅចូលរួមចំណែកអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជាឱ្យសម្រេចជោគជ័យប្រកបដោយប្រសិទ្ធភាព និងចីរភាព ។



## ៤.៣. កិច្ចសហការជាមួយកម្មវិធីអភិវឌ្ឍសហប្រជាជាតិ (UNDP)






ក្នុងឆ្នាំ ២០២០, វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសហការជាមួយដៃគូអភិវឌ្ឍដូចជា: UNDP Regional, UNWomen Regional, UNDP កម្ពុជា, និង CCCA ក្នុងការរៀបចំកម្មសិក្ខាសាលា និងសិក្ខាសាលាបណ្តុះបណ្តាលកម្រិតខ្ពស់ស្តីពី “**ការពង្រឹងអភិបាលកិច្ចនៃហិរញ្ញវត្ថុការប្រែប្រួលអាកាសធាតុដើម្បីសមភាពយេនឌ័រ**”ចំនួន **៤ វគ្គ÷** វគ្គទី ១ ប្រព្រឹត្តទៅនាថ្ងៃទី ២៤-២៨ ខែ សីហា ឆ្នាំ ២០២០ ជូនគ្រូបង្គោលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងកិច្ចការនារី, ក្រសួងបរិស្ថាន, និងសាកលវិទ្យាល័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, វគ្គទី ២ ប្រព្រឹត្តទៅនាថ្ងៃទី ២៨ ខែ កញ្ញា រហូតដល់ថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០២០ ជូនមន្ត្រីរាជការមកពីមន្ទីរសាធារណការនិងដឹកជញ្ជូន នៃរាជធានី-ខេត្តទាំង ២៥ , វគ្គទី ៣ ប្រព្រឹត្តទៅនាថ្ងៃទី ៤-៩ ខែ តុលា ឆ្នាំ ២០២០ ជូនមន្ត្រីរាជការមកពីមន្ទីរអភិវឌ្ឍជនបទ នៃរាជធានី-ខេត្តទាំង ២៥, និង វគ្គទី ៤ ប្រព្រឹត្តទៅនាថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០២០ នៅលើប្រព័ន្ធវីដេអូ Zoom ដោយមានសិក្ខាកាមគោលដៅជាថ្នាក់ដឹកនាំកម្រិតបច្ចេកទេស របស់ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍជនបទ និងអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ពិធីបើកវគ្គបណ្តុះបណ្តាលនេះបានប្រព្រឹត្តទៅក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារកសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, លោក សាមូអែល ហ៉ាតទីស** (Samuel Hurtig) ប្រធានផ្នែកសហប្រតិបត្តិការនៃស្ថានទូតស៊ុយអ៊ែត ប្រចាំព្រះរាជាណាចក្រកម្ពុជា និង **ឯកឧត្តម ជា ចន្ទន៍ធូ អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍដោយចីរភាព** ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍជនបទ, ក្រសួងបរិស្ថាន, ក្រសួងកិច្ចការនារី, និងតំណាងអង្គការអន្តរជាតិរួមមាន÷ UNDP Regional, UNWomen Regional, UNDP កម្ពុជា, និង CCCA, ព្រមទាំងគ្រូឧទ្ទេស និងសិក្ខាកាមសរុបប្រមាណ **៩០ នាក់ ។** វគ្គបណ្តុះបណ្តាលទាំងនេះត្រូវបានរៀបចំឡើងក្នុងគោលបំណង ដើម្បីពង្រឹងពង្រីក និងលើកកម្ពស់ចំណេះដឹង កសាងនិងអភិវឌ្ឍសមត្ថភាពលើជំនាញគ្រប់គ្រងហិរញ្ញវត្ថុជាពិសេស “**ការពង្រឹងអភិបាលកិច្ចនៃហិរញ្ញវត្ថុការប្រែប្រួលអាកាសធាតុ ដើម្បីសមភាពយេនឌ័រ**” ។

## ៤.៤. កិច្ចសហការចែករំលែកបទពិសោធន៍និងចំណេះដឹងជាមួយ PFM Academy ប្រទេសមីយ៉ាន់ម៉ា




នារសៀលថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០២០ មានរៀបចំកិច្ចប្រជុំចែករំលែកបទពិសោធន៍រវាង វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង Myanmar PFM Academy តាមប្រព័ន្ធវីដេអូ (video conference) ដែលចូលរួមដឹកនាំដោយ **ឯកឧត្តម មាស សុខសេនសាន អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និង សម្របសម្រួលដោយធនាគារពិភពលោកប្រចាំប្រទេសមីយ៉ាន់ម៉ា និង ប្រទេសកម្ពុជា សំដៅចែករំលែកបទពិសោធន៍នៃការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការងារកសាងនិងអភិវឌ្ឍសមត្ថភាពនៅព្រះរាជាណាចក្រកម្ពុជា ជូន Myanmar PFM Academy ។ ក្នុងជំនួបនេះ **លោក ម៉ៅ បូរាណ នាយករង និងជាប្រធានគម្រោងកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** បានលើកឡើងក្នុងន័យចែករំលែកចំណេះដឹងថា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារកសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**, វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានអនុវត្តយ៉ាងសកម្មលើការងារកសាងនិងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ដោយទទួលបានសមិទ្ធផលត្រចះត្រចង់ និងបានចូលរួមចំណែកដ៏សំខាន់ក្នុងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅគ្រប់ដំណាក់កាល ។ ទន្ទឹមនោះ នាយករងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏បានលើកឡើងពីបទពិសោធន៍បច្ចេកទេសលើការកសាងនិងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការដោយផ្តោតលើ÷ (១). ការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការ, (២). ការរៀបចំកសាងធនធានគ្រូបង្គោល, (៣). ការអភិវឌ្ឍវិធីសាស្ត្រនិងគរុកោសល្យគ្រូបង្គោល, (៤). ការប៉ាន់ប្រមាណតម្រូវការបណ្តុះបណ្តាល និងការរៀបចំផែនការបណ្តុះបណ្តាលនិងវិក្រឹតការ, (៥). ក្របខណ្ឌត្រួតពិនិត្យតាមដាន និងការវាយតម្លៃ, និង (៦). អនុសាសន៍មួយចំនួនលើការកសាងនិងអភិវឌ្ឍសមត្ថភាពនៅព្រះរាជាណាចក្រកម្ពុជា ជូនដល់គណៈប្រតិភូ Myanmar PFM Academy ផងដែរ ។

## ៤.៥. កិច្ចសហការជាមួយវិទ្យាស្ថានហិរញ្ញវត្ថុ និងអភិវឌ្ឍអាស៊ី-ប៉ាស៊ីភិច (AFDI)




នាថ្ងៃទី ១៦-១៨ ខែ វិច្ឆិកា ឆ្នាំ ២០២០ និង ថ្ងៃទី ១៤-១៦ ខែ ធ្នូ ឆ្នាំ ២០២០, វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងវិទ្យាស្ថានហិរញ្ញវត្ថុ និង អភិវឌ្ឍអាស៊ី- ប៉ាស៊ីភិច (AFDI) នៃទីក្រុងសៀងហៃ ប្រទេសចិន បានសហការរៀបចំវគ្គបណ្តុះបណ្តាល ពីចម្ងាយចំនួន **២ វគ្គ** ស្តីពី **"ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)"** និងវគ្គបណ្តុះបណ្តាល **"ភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជន (PPPs) : បទពិសោធន៍ប្រទេសចិន"** ជូនថ្នាក់ដឹកនាំថ្នាក់នាយកដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នសរុបចំនួន **៩៨ នាក់** ក្រោមការដឹកនាំរបស់ **ឯកឧត្តមនាយកវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារកសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការចូលរួមពីតំណាង AFDI នៃប្រទេសចិន ។ វគ្គសិក្សាទាំងពីរនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងចូលរួមចំណែក ក្នុងការពង្រឹងពង្រីកសមត្ថភាព, លើកកម្ពស់ការយល់ដឹង, ដកស្រង់បទពិសោធន៍ពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, លើកកម្ពស់ការយល់ដឹងពីការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS), និងលើកកម្ពស់ការយល់ដឹងអំពីភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជន (PPPs) ។

## ៥. កម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី ក្រោមកិច្ចសហការជាមួយក្រសួងស្ថាប័ន

ក្រោមការដឹកនាំ និងណែនាំចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារកសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**, វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំកម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី សិក្ខាសាលាបណ្តុះបណ្តាល និងសិក្ខាសាលាចែករំលែកចំណេះដឹង ជូនថ្នាក់ដឹកនាំកម្រិតបច្ចេកទេស និងមន្ត្រីជំនាញពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយទទួលបានលទ្ធផលប្រកបដោយជោគជ័យ ។



### ៥.១. កម្មវិធីបណ្តុះបណ្តាលសម្រាប់ក្រសួងស្ថាប័ននៅថ្នាក់ជាតិ

### ៥.១.១. វគ្គបណ្តុះបណ្តាលតម្រង់ទិសជូនមន្ត្រីរាជការក្របខណ្ឌឆ្នាំ ២០១៦-២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នាព្រឹកថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០២០ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនាយកដ្ឋានបុគ្គលិកនៃអគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសហការរៀបចំបើកវគ្គបណ្តុះបណ្តាលតម្រង់ទិសជូនមន្ត្រីរាជការក្របខណ្ឌឆ្នាំ ២០១៦-២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ពិធីបើកវគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅក្រោមការដឹកនាំរបស់ **លោក អៀង សុភ័ក្រ្ត ប្រធាននាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ** ជាតំណាងរបស់ **ឯកឧត្តមនាយកវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការចូលរួមពីតំណាងអគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ វគ្គបណ្តុះបណ្តាលតម្រង់ទិសនេះ ត្រូវបានរៀបចំឡើងចំនួន **៣ វគ្គ** មានរយៈពេល ៥ ថ្ងៃ ក្នុងមួយវគ្គៗ ។ វគ្គទី ១ ថ្ងៃទី ២៤ - ២៨ ខែ កុម្ភៈ ឆ្នាំ២០២០, វគ្គទី ២ ថ្ងៃទី ២-៦ ខែ មីនា ឆ្នាំ ២០២០ និង វគ្គទី ៣ ថ្ងៃទី ៩-១៣ ខែ មីនា ឆ្នាំ ២០២០ ក្នុងគោលបំណងដើម្បីពង្រឹងពង្រីក លើកកម្ពស់ចំណេះដឹង និងអភិវឌ្ឍសមត្ថភាពជូនមន្ត្រីក្របខណ្ឌថ្មីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយផ្តោតសំខាន់ទៅលើប្រធានបទដូចជា÷ សេដ្ឋកិច្ចកម្ពុជា, ការរៀបចំថវិកា, ការអនុវត្តថវិកា, លទ្ធកម្មសាធារណៈ, ច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល, គោលនយោបាយរូបិយវត្ថុ, កិច្ចការរដ្ឋបាលសាធារណៈ និង រចនាសម្ព័ន្ធនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ សិក្ខាកាមដែលបានចូលរួមវគ្គសិក្សានេះ បានសម្តែងពីការពេញចិត្ត និងវាយតម្លៃខ្ពស់ចំពោះវគ្គសិក្សា និងបានប្តេជ្ញាយកចំណេះដឹងនិងបទពិសោធន៍ដែលបានចែករំលែកនៅក្នុងវគ្គសិក្សា យកទៅអនុវត្តក្នុងការដ្ឋានការងាររៀងៗខ្លួន ឱ្យសម្រេចបានលទ្ធផលកាន់តែល្អប្រសើរថែមទៀត ។

## ៥.១.២ វគ្គបណ្តុះបណ្តាលស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងការរៀបចំត្រួតពិនិត្យវាយតម្លៃលើថវិកាកម្មវិធី





នាព្រឹកថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០២០, នៅសណ្ឋាគារសុខាភ្នំពេញ រាជធានីភ្នំពេញ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី “**ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងការរៀបចំត្រួតពិនិត្យវាយតម្លៃលើថវិកាកម្មវិធី** ” ជូនសិក្ខាកាមដែលជាមន្ត្រីរាជការ នៃអង្គភាពប្រឆាំងអំពើពុករលួយ ។ ពិធីបើកវគ្គបណ្តុះបណ្តាលប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារកសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និង **ឯកឧត្តម ទូច ស៊ុនណារី អនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ** និងមានការអញ្ជើញចូលរួមដោយ ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ថ្នាក់ដឹកនាំអង្គភាពប្រឆាំងអំពើពុករលួយ, គ្រូឧទ្ទេស និងសិក្ខាកាមសរុបប្រមាណ **១០០ នាក់** ។

វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងក្នុងគោលបំណង ដើម្បីពង្រឹងសមត្ថភាពនិងប្រសិទ្ធភាពក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និង ការត្រួតពិនិត្យវាយតម្លៃលើថវិកាកម្មវិធី ដើម្បីឆ្លើយតបទៅនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ។

## ៥.២ កម្មវិធីបណ្តុះបណ្តាលសម្រាប់ថ្នាក់ក្រោមជាតិ





### ៥.២.១ វគ្គបណ្តុះបណ្តាលស្តីពី នីតិវិធីគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ

ក្នុងឆ្នាំ ២០២០, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី “**នីតិវិធីគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ**” ចំនួន **៣ វគ្គ** ជូនថ្នាក់ដឹកនាំ និងមន្ត្រីជំនាញទទួលបន្ទុកការងារពាក់ព័ន្ធការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើរពន្ធរបស់រដ្ឋបាលរាជធានីខេត្ត មន្ទីរអង្គភាព និងរដ្ឋបាលក្រុង ស្រុក នៃខេត្តចំនួន ៣ ។ វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងក្នុងគោលបំណង ពង្រឹងពង្រីកសមត្ថភាព និងលើកកម្ពស់ការយល់ដឹងជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៅថ្នាក់ក្រោមជាតិ ដើម្បីចូលរួមចំណែកលើកកម្ពស់តម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ នៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធឱ្យបានត្រឹមត្រូវតាមគោលការណ៍បច្ចេកទេស និង អនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនិង ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ។



ក្នុងនោះនាព្រឹកថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០២០, នៅសណ្ឋាគាររ៉ាហ្វលទ្បឺរ៉ូយ៉ាល់,រាជធានីភ្នំពេញ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបើកវគ្គបណ្តុះបណ្តាលស្តីពី “**នីតិវិធីគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ** ” ជូនសិក្ខាកាមគោលដៅ ដែលជាអភិបាលរងរាជធានីខេត្ត, មន្ត្រីរាជការជាថ្នាក់ដឹកនាំកម្រិតជំនាញទទួលបន្ទុកការងារពាក់ព័ន្ធការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើរពន្ធនៃរដ្ឋបាលរាជធានី-ខេត្ត និងប្រធាន/អនុប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទូទាំងប្រទេស ។ ពិធីបើកវគ្គបណ្តុះបណ្តាលនេះ បានប្រព្រឹត្តទៅក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារកសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការចូលរួមដោយ ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ្រូឧទ្ទេស និងសិក្ខាកាមសរុបប្រមាណ **១០០ នាក់** ។



ហើយនាព្រឹកថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០២០ នៅសណ្ឋាគារខេមរាបាត់ដំបង ១ ខេត្តបាត់ដំបង និងព្រឹកថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០២០ នៅសណ្ឋាគារកំពតឪយ៉ាម៉ង់ ខេត្តកំពត, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបន្តបើកវគ្គបណ្តុះបណ្តាលស្តីពី "នីតិវិធីគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ" ចំនួន ២ វគ្គ ជូនសិក្ខាកាមគោលដៅ ដែលជាមន្ត្រីរាជការទទួលបន្ទុកការងារពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៃមន្ទីរអង្គភាពជំនាញ និងរដ្ឋបាលក្រុង ស្រុក ដោយវគ្គបណ្តុះបណ្តាលទាំង **២ វគ្គ** បានប្រព្រឹត្តទៅក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ពេជ្រ សម្បត្តិ អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការនិងជាប្រធានក្រុមការងារកសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។**

## ៦. អនុស្សរណៈយោគយល់រវាងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍជាតិ-អន្តរជាតិ

### ៦.១. អនុស្សរណៈយោគយល់រវាង វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាលាជាតិរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ





ក្រោមការដឹកនាំ និងណែនាំចង្អុលបង្ហាញជាបន្តបន្ទាប់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារកសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**, នារសៀលថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០២០, នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់រវាងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាលាជាតិរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ ។ ពិធីនេះត្រូវបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារកសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និង **ឯកឧត្តម គុល ធីរក្ស រដ្ឋលេខាធិការក្រសួងមហាផ្ទៃ** ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ អនុរដ្ឋលេខាធិការ អគ្គនាយក លោក លោកស្រី ជាថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ។ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** បានបញ្ជាក់ថា ការចុះអនុស្សរណៈយោគយល់គ្នានេះ គឺបង្ហាញពីការយកចិត្តទុកដាក់ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួងទាំងពីរ ក្នុងការលើកកម្ពស់ការកសាងនិងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការសម្រាប់អនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង កម្មវិធីកែទម្រង់គន្លឹះៗដទៃទៀត ស្របតាមចក្ខុវិស័យរាជរដ្ឋាភិបាលដែលចាត់ទុកថា ការកែទម្រង់ជាឧបករណ៍គោលនយោបាយគន្លឹះសម្រាប់ដោះស្រាយបញ្ហាប្រឈម និងបង្កើតកាលានុវត្តភាពថ្មីឆ្ពោះទៅមុខបន្តទៀត ។

### ៦.២. អនុស្សរណៈយោគយល់រវាងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាលារដ្ឋបាលសាធារណៈ (CSC) និងមូលនិធិតេម៉ាសេកអន្តរជាតិ (TFI) ប្រទេសសិង្ហបុរី

Civil Service College Singapore

TEMASEK FOUNDATION International

ក្នុងឆ្នាំ ២០២០, វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, សាលារដ្ឋបាលសាធារណៈ (CSC) និងមូលនិធិតេម៉ាសេកអន្តរជាតិ (TFI) ប្រទេសសិង្ហបុរី បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ក្នុងគោលបំណងដើម្បីពង្រឹងពង្រីក កសាងនិងអភិវឌ្ឍសមត្ថភាពជូនមន្ត្រីរាជការទទួលបន្ទុកការងារគ្រប់គ្រងហិរញ្ញវត្ថុ ក៏ដូចជាធ្វើការចែករំលែកបទពិសោធន៍ដ៏មានតម្លៃរវាងព្រះរាជាណាចក្រកម្ពុជា និង ប្រទេសសិង្ហបុរី លើការងារអភិវឌ្ឍធនធានមនុស្សដ៏មានសារសំខាន់ ។ អនុសារណៈយោគល់នេះបានបើកឱកាសឱ្យមានវគ្គបណ្តុះបណ្តាលចំនួន ២ វគ្គ ត្រូវបានសហការរៀបចំឡើងនៅក្នុងឆ្នាំ ២០២០ សម្រាប់គ្រូបង្គោលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ វគ្គបណ្តុះបណ្តាលបន្តបន្ទាប់ចំនួន ៣ ទៀតនឹងរៀបចំនៅក្នុងឆ្នាំ ២០២១ ។ និងការអនុវត្តថែមទៀតដល់ការងារកសាងនិងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការនៅកម្ពុជា ។

## ៦.៣. អនុស្សរណៈយោគយល់រវាងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងកម្មវិធីអភិវឌ្ឍសហប្រជាជាតិ (UNDP)

នាថ្ងៃ ៩ ខែ កុម្ភៈ ឆ្នាំ ២០១៩, វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងកម្មវិធីអភិវឌ្ឍសហប្រជាជាតិ (UNDP) បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ដើម្បីបន្តអនុវត្តគម្រោងកម្មវិធីបណ្តុះបណ្តាលស្តីពី “**ការពង្រឹងអភិបាលកិច្ចនៃហិរញ្ញវត្ថុការប្រែប្រួលអាកាសធាតុ ដើម្បីពង្រឹងសមភាពយេនឌ័រ**” ជូនថ្នាក់ដឹកនាំ, មន្ត្រីជំនាញ និងគ្រូបង្គោលរបស់វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងបរិស្ថាន, ក្រសួងកិច្ចការនារី, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍជនបទ, និងសាកលវិទ្យាល័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ អនុសារណៈយោគល់នេះបានបើកឱកាសឱ្យមានវគ្គបណ្តុះបណ្តាលចំនួន ៤ វគ្គ ត្រូវបានសហការរៀបចំឡើង នៅក្នុងឆ្នាំ ២០២០ សម្រាប់គ្រូបង្គោលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ៦.៤. អនុស្សរណៈយោគយល់រវាងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាកលវិទ្យាល័យបច្ចេកវិទ្យាណាន់យ៉ាង (NTU) និងមូលនិធិតេម៉ាសេកអន្តរជាតិ (TFI) ប្រទេសសិង្ហបុរី

នាថ្ងៃទី ១ ខែ កញ្ញាឆ្នាំ ២០១៦, វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាកលវិទ្យាល័យបច្ចេកវិទ្យាណាន់យ៉ាង (NTU) និងមូលនិធិតេម៉ាសេកអន្តរជាតិ (TFI) ប្រទេសសិង្ហបុរី បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពីការបណ្តុះបណ្តាលនិងវិក្រឹតការ កសាងនិងអភិវឌ្ឍសមត្ថភាពជូនថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ លើជំនាញការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងភាពជាអ្នកដឹកនាំក្នុងវិស័យសាធារណៈ សម្រាប់ការចែករំលែក និងផ្លាស់ប្តូរបទពិសោធន៍រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសសិង្ហបុរី ។



## ៧. ការសិក្សាស្រាវជ្រាវស្តីពីការពិនិត្យលទ្ធភាពក្នុងការរៀបចំប្រព័ន្ធសិក្សាពីចម្ងាយ (Distance Learning System)

ប្រតិបត្តិតាមការចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងក្រោមការដឹកនាំចង្អុលបង្ហាញជាបន្តបន្ទាប់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារកសាងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**, ក្នុងគោលដៅដើម្បីលើកកម្ពស់ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការឱ្យកាន់តែមានប្រសិទ្ធភាព ឆ្លើយតបនឹងការរងផលប៉ះពាល់នៃមេរោគកូវីដ-១៩ (COVID-19) ក៏ដូចជាការត្រៀមខ្លួនក្នុងករណីអាចនឹងមានផលប៉ះពាល់នានាសម្រាប់ពេលអនាគត, វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានកំពុងរៀបចំប្រព័ន្ធសិក្សាពីចម្ងាយ (Distance Learning System) ដើម្បីធានានិរន្តរភាព នៃដំណើរការបណ្តុះបណ្តាលនិងវិក្រឹតការ សំដៅពង្រឹងពង្រីក និងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ក្នុងឆ្នាំ ២០២០ នេះ, ក្រុមការងារវិទ្យាស្ថានបានសិក្សាលទ្ធភាពក្នុងការអនុវត្តប្រព័ន្ធសិក្សាពីចម្ងាយ (Distance Learning System) សម្រាប់រៀបចំកម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការជូនមន្ត្រីទទួលបន្ទុកគ្រប់គ្រងហិរញ្ញវត្ថុរបស់មន្ទីរជំនាញជុំវិញរាជធានី-ខេត្ត ព្រមទាំងបានប្រមូលធាតុចូលសំខាន់ៗ ក្នុងការបង្កើនគុណភាពប្រសិទ្ធភាព និងតម្លាភាពនៃវគ្គបណ្តុះបណ្តាល ។



